ព្រឹត្តិបត្រព័ត៌មាន

# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

NGO Committee on the Rights of the Child

NGO CRC

ឆ្នាំទី៤ លេខ៩ ខែមករា_មីនា ឆ្នាំ២០០៦

**មាតិកា** **ទំព័រ**

ការផ្តល់អាហារូបករណ៍ដោយUWCដល់សិស្សកម្ពុជា........................១

ការរៀនបែបសិស្សមជ្ឈមណ្ឌល........៣

សិក្ខាសាលាបណ្តុះបណ្តាលអ្នកអប់រំបន្តស្តីពីការបញ្ជ្រាបការចូលរួមរបស់កុមារ..៤

គ្រឿងញៀនជាដំបៅរបស់សង្គមជាតិ....៤

មណ្ឌលថ្ងៃល្អ........................៥

សមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា.........................៦

ការលើកកំពស់ការអនុវត្តន៍សិទ្ធិកុមារក្នុងចំនោមមន្ត្រីសុខាភិបាល...........៨

ករណីរំលោភបំពានលើកុមារពីខែមករា ដល់ខែមីនា ឆ្នាំ២០០៦......១០

អង្គការសមាជិកថ្មីរបស់NGOCRC ...១១

## ការផ្តល់អាហារូបករណ៍ដោយ United World Colleges ដល់សិស្សកម្ពុជា

United World Colleges (UWC) ជាចលនានៃការអប់រំមួយដែលសិស្សនៅលើពិភពលោកត្រូវបានជ្រើសរើសដោយសមត្ថភាពរបស់ខ្លួនគេផ្ទាល់ ឱ្យមកសិក្សានៅ UWC ហើយត្រូវបានផ្តល់នូវការរស់នៅក្នុងបរិស្ថានមួយក្នុងពិភពលោកដែលប្រកបដោយការឯកភាព សន្តិភាព និងយុត្តិធម៌។ សព្វថ្ងៃនេះមាន UWCចំនួន១០នៅលើពិភពលោក រួមមាន នៅប្រទេសអង់គ្លេស សាំងហ្គាពួរ កាណាដា វេណេស៊ុយអេឡា សហរដ្ឋអាមេ_រិក អ៊ីតាលី ស្វីស ឥណ្ឌា ន័រវេស្ស៍ និងហុងកុង។ នេះជាលើកទី២ហើយ ដែល UWC បានផ្តល់អាហារូបករណ៍ដល់សិស្សកម្ពុជា តាមរយៈអង្គការ "មណ្ឌលកុមារដើម្បីសុភមង្គល(CCH)"។

**លោក ម៉ិច សុខា** ប្រធានគណៈកម្មាធិការជាតិរបស់UWCប្រចាំ



កម្ពុជា និងជាប្រធានមណ្ឌលកុមារដើម្បីសុភ_មង្គល បានឱ្យដឹងថា សិស្សដែលបានដាក់ពាក្យប្រលងឆ្នាំនេះ មានចំនួន ៣៤០នាក់ មកពីខេត្តកណ្តាល តាកែវ កំពត ភ្នំពេញ បន្ទាយមានជ័យ ពោធិសាត់ និងសៀមរាប ដែលក្នុងនោះ ចំនួន១៧១នាក់ជាសិស្សស្រី។ ចំណែកឯលក្ខខណ្ឌនៃការដាក់ពាក្យប្រលងបាន គឺសិស្សដែលមានអាយុពី១៦ដល់១៩ឆ្នាំ កំពុងសិក្សាថ្នាក់ទី១១ និងទី១២ នៅទូទាំងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំនេះ ការប្រលងបានប្រារព្ធធ្វើ២លើក គឺលើកទី១ នៅភ្នំពេញ នៅថ្ងៃទី២១ខែមករា ឆ្នាំ២០០៦ និងលើកទី២ នៅខេត្តពោធិសាត់ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៦។

លោកបន្តថា ជារៀងរាល់ឆ្នាំ នៅពេលដែលប្រកាសជ្រើសរើស អង្គការតែងធ្វើការផ្សព្វផ្សាយតាមរយៈ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) សាលានៅរាជធានីភ្នំពេញ មន្ទីរអប់រំខេត្ត និងសាលាតាមខេត្តនានា នៅចុងខែតុលា និងចាប់ផ្តើមទទួលពាក្យនៅខែធ្នូ។

លោកមានប្រសាសន៍ទៀតថា សិស្សដែលប្រលងជាប់ នឹងត្រូវរៀនថ្នាក់ទី១១ រយៈពេល២ឆ្នាំ ហើយទទួលបានជំនួយឧបត្ថម្ភដូចជា ស្នាក់នៅ ហូបចុក សិក្សា ដំណើរកំសាន្ត សំបុត្រយន្តហោះ លិខិតឆ្លងដែន ទិដ្ឋាការ។ល។ ក្រោយពេលរៀនចប់រយៈពេល២ឆ្នាំ ពួកគេត្រូវរកអាហារូបករណ៍ដោយខ្លួនឯង។

**លោក ម៉ិច សុខា** បញ្ជាក់ទៀតថា "នេះជាលើកទី២ ដែលUWCបានផ្ដល់អាហារូបករណ៍ដល់សិស្សកម្ពុជា ដែលលើកទី១ជ្រើសរើសយក១នាក់ គឺជាប់សិស្សមកពីខេត្តបន្ទាយមានជ័យ ទៅរៀននៅប្រទេសន័រវេស្ស៍ និងលើកនេះ គឺជ្រើសរើសយក៤នាក់ទៅរៀននៅប្រទេសអាមេរិក ន័រវេស្ស៍ អង់គ្លេស និងកូស្តារីកា។ ចំណែកសិស្សដែលប្រលងជាប់ចំនួន៤នាក់មានសិស្សស្រីចំនួន២នាក់មកពីរាជធានីភ្នំពេញ និងខេត្តបន្ទាយមានជ័យ និងប្រុស២នាក់ទៀតមកពីខេត្តបន្ទាយមានជ័យ។ ពួកគេនឹងចេញទៅនៅក្នុងខែសីហា ដោយត្រូវឱ្យពួកគេបំប៉នភាសាអង់គ្លេសរយៈពេល៤ខែសិន"។

ជាទីបញ្ចប់ លោកបន្តថា "ការផ្ដល់អាហារូបករណ៍នេះ មានសារៈសំខាន់ណាស់ គឺយើងនឹងមានធនធានមនុស្សលំដាប់អន្តរជាតិ ដែលអាចចូលរួមជួយកសាងសង្គមជាតិប្រកបដោយការទទួលខុសត្រូវ និងសន្តិភាព។

## ខាងក្រោមនេះជាសំលេងរបស់កុមារក្រោយពេលប្រលងជាប់៖



**ប្អូនប្រុស មាស ឧត្តម** អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យសម្ដេចឪ ខេត្តបន្ទាយមានជ័យ ប្រលងជាប់ទៅរៀននៅប្រទេសអាមេរិក ប្រាប់ថា "ខ្ញុំដឹងព័ត៌មាននៃការប្រលងនេះតាមរយៈមិត្តភ័ក្តដែលបានប្រលងជាប់ឆ្នាំមុនទៅប្រទេសន័រវេស្ស៍ គេឱ្យខ្ញុំមើលនៅលើវេបសាយ www.uwc.org ហើយនិងតាមរយៈគ្រូ"។ "ខ្ញុំសប្បាយរីករាយរំភើបណាស់ ព្រោះកាលពីមុនមិនដែលបានគិតទេថា នឹងបានទៅរៀននៅក្រៅប្រទេស"។ "ទៅថ្ងៃអនាគតខ្ញុំចង់ធ្វើជាវិស្វករ ព្រោះចង់ជួយអភិវឌ្ឍប្រទេសជាតិយើង ដោយមើលឃើញថា ជាប្រទេសនៅមានចំនុចខ្វះខាតជាច្រើន"។ "ដើម្បីឱ្យសំរេចនូវគោលបំណង ខ្ញុំត្រូវតែខិតខំរៀនមុខវិជ្ជាវប្បធម៌ទូទៅ គណិត រូប គីមី កុំព្យូទ័រ និងអង់គ្លេស"។



ចំណែកឯ **កុមារា នឿម យិនដា** អាយុ១៦ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យសម្ដេចឪ ខេត្តបន្ទាយមានជ័យ ប្រាប់ថា "ខ្ញុំមានអារម្មណ៍សប្បាយចិត្តមែនទែនដែលប្រលងជាប់អាហារូបករណ៍ទៅរៀននៅប្រទេសអង់គ្លេស។ អាហារូបករណ៍នេះ គឺល្អណាស់វាជួយបណ្ដុះបណ្ដាលកូនខ្មែរ ដែលត្រូវតាមគោលបំណងរបស់ខ្ញុំចង់បាន"។ "ទៅថ្ងៃអនាគត ខ្ញុំចង់ធ្វើជាមេធាវី ព្រោះប្រទេសកម្ពុជាអនុវត្តលទ្ធិប្រជាធិបតេយ្យនៅមិនទាន់ពេញលេញនៅឡើយ"។ "ដើម្បីឱ្យសំរេចបំណង ខ្ញុំនឹងខំរៀនអស់ពីសមត្ថភាព បើមានឱកាស ខ្ញុំនឹងរៀនបន្តនៅប្រទេសល្អៗនៅលើពិភពលោក ដើម្បីយកចំណេះដឹងមកអភិវឌ្ឍប្រទេសកម្ពុជា"។



**កុមារី ជិន ស្រីនុជ** អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យបាក់ទូក រាជធានីភ្នំពេញ ប្រាប់ថា "ខ្ញុំមានអារម្មណ៍សប្បាយ និងរំភើបមែនទែននៅពេលដឹងថាប្រលងជាប់ដោយមិននឹកស្មានដល់ ហើយពេលប្រាប់ប៉ាម៉ាក់ គាត់ក៏សប្បាយ ហើយវាជាការសងគុណដល់ឪពុកម្ដាយមួយផ្នែក"។

"ខ្ញុំប្រលងជាប់ទៅរៀននៅ Costa Rica ជាសាលាដែលខ្ញុំចង់ទៅរៀន ព្រោះនៅទីនោះអាកាសធាតុប្រហាក់ប្រហែលនឹងស្រុកខ្មែរ ងាយស្រួលរស់នៅ ម្យ៉ាងទៀត អាចឱ្យយើងប្រើសំលៀកបំពាក់ខ្មែរ ដែលជាការចូលរួមចំណែក ផ្សព្វផ្សាយនូវវប្បធម៌ខ្មែរផងដែរ"។ "ទៅថ្ងៃអនាគត ខ្ញុំចង់ក្លាយជាអ្នកវិទ្យាសាស្ត្រមួយរូប ពីព្រោះខ្ញុំចង់អភិវឌ្ឍប្រទេសជាតិ ដូចជាវារីអគ្គិសនី ប្រព័ន្ធប្រលាយទឹកដែលទាក់ទងនឹងបច្ចេកវិទ្យាថ្មី"។

"ពេលទៅរៀននៅCosta Rica ខ្ញុំត្រូវតែខិតខំរៀនឱ្យបានខ្លាំងមែនទែន ដើម្បីចេះពេញលេញទៅតាមខ្នាតអន្តរជាតិថ្នាក់ពិភពលោក និងដើម្បីឱ្យបានអាហារូបករណ៍នៅប្រទេសនោះបន្តទៀត។ ជាងនេះទៀតខិតខំផ្សព្វផ្សាយពីវប្បធម៌ខ្មែរ ដូចជាសំលៀកបំពាក់ខ្មែរ រមណីយដ្ឋាននានា ដើម្បីឱ្យភ្ញៀវទេសចរកាន់តែចូលមកប្រទេសកម្ពុជាយើងច្រើនទៀត។"

"ដើម្បីឱ្យសំរេចបំណង និងគោលដៅដែលបានកំណត់ ខ្ញុំត្រូវខិតខំរៀន ពេលរៀននៅសាលាខំស្ដាប់គ្រូ ស្រាវជ្រាវបន្ថែម ហាត់ធ្វើលំហាត់ដោយខ្លួនឯង មិនយល់ត្រង់ណាត្រូវសួរគ្រូ ពេលនៅផ្ទះត្រូវស្ដាប់ឪពុកម្ដាយ បងប្អូន មិត្តភ័ក្ត ណែនាំទូន្មានប្រៀនប្រដៅ និងចំណេះដឹងវប្បធម៌ទូទៅផ្សេងៗ ហើយជាពិសេសទៀត គឺមិនត្រូវរំក្សត់ខ្លួនឯង ហើយត្រូវមានការពិន័យលើខ្លួនឯង បើខ្ញុំមិនបានធ្វើតាមអ្វីដែលខ្ញុំកំណត់"។

ជាទីបញ្ចប់ "ខ្ញុំគិតថាអាហារូបករណ៍នេះ គឺល្អណាស់សំរាប់កូនខ្មែរ សូមឱ្យសិស្សជំនាន់ក្រោយ ត្រូវតែមានគំនិតខិតខំរៀនឡើង ដើម្បីជួយកសាងប្រទេសជាតិរបស់ខ្លួន ហើយបើបានអាហារូបករណ៍ទៅរៀននៅក្រៅប្រទេសហើយ សូមខិតខំ ព្រមទាំងមានគំនិតស្នេហាជាតិផង មិនត្រូវទៅរៀនហើយ ពេលចប់មិនត្រឡប់មកប្រទេសរបស់ខ្លួនវិញនោះទេ ត្រូវតែត្រឡប់មកប្រទេសរបស់ខ្លួនវិញ ដើម្បីអភិវឌ្ឍប្រទេសជាតិ។ កុំឱ្យដូចពាក្យគេថា

តទៅទំព័រទី១២

# ការរៀនបែបសិស្សមជ្ឈមណ្ឌល
## Child Centered Learning

សិក្ខាសាលាស្តីពីការរៀនបែបសិស្សមជ្ឈមណ្ឌល ត្រូវបានរៀបចំដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) ដោយមានការសហការជាមួយមណ្ឌលកុមារដើម្បីសុភមង្គល (CCH) និង United World Colleges South East Asia (UWC SEA) កាលពីថ្ងៃទី៣០_៣១ ខែមីនា ឆ្នាំ២០០៦។ សិក្ខាសាលានេះ មានសិក្ខាកាមចូលរួមចំនួន៤៣នាក់ មកពីអង្គការសមាជិក និងបុគ្គលិករបស់ NGOCRC ក្រោមជំនួយឧបត្ថម្ភថវិការបស់ UWC SEA នៅសាំងហ្គាពួរ និងអង្គការស្ពានដើម្បីសន្តិភាព(Bridges Across Borders)។ លោក Kevin Morley តំណាងមកពី UWC SEA ជាគ្រូឧទេសក្នុងសិក្ខាសាលានេះ។

**លោក ជា ពិជ័ន** ប្រធាន NGO CRC មានប្រសាសន៍នាឱកាសបើកអង្គការសិក្ខាសាលាថា «សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណង ដើម្បីឱ្យអ្នកដែលធ្វើការផ្ទាល់ជាមួយកុមារ ពិសេសគឺគ្រូបង្រៀនកុមារ ធ្វើយ៉ាងណាឱ្យកុមារមានការចូលរួមក្នុងពេលសិក្សារបស់ពួកគេពិតប្រាកដពេញលេញ ដើម្បីឱ្យមានការផ្លាស់ប្តូរនូវការសិក្សាឈានទៅរកការរីកចំរើន និងការអភិវឌ្ឍន៍។ ម្យ៉ាងទៀតគ្រូ ឬអ្នកថែទាំកុមារត្រូវយកចិត្តទុកដាក់ ដឹងពីតំរូវការរបស់កុមារ និងជួយតំរង់ទិសក្នុងការអភិវឌ្ឍន៍ខ្លួនរបស់កុមារ ព្រោះកុមារនឹងក្លាយជាមនុស្សពេញវ័យទៅជាម្តាយ ឪពុករបស់គេ ហើយមនុស្សធំ ត្រូវធ្វើយ៉ាងណាដើម្បីជាគំរូល្អដល់កុមារ។»

លោក David Pred នាយកប្រចាំប្រទេសកម្ពុជារបស់អង្គការស្ពានដើម្បីសន្តិភាព (Bridges Across Borders) មានប្រសាសន៍នាឱកាសថ្លែងសន្ទរកថាក្នុងសិក្ខាសាលានោះដែរថា «សិក្ខាសាលានេះ នឹងបង្វែរការរៀនរបស់សិស្សឱ្យទៅជាការរៀនបែបសិស្សមជ្ឈមណ្ឌល ព្រោះកាលពីមុនគ្រូបង្រៀនដោយការនិយាយប្រាប់ និងពន្យល់ ហើយសិស្សអង្គុយតែស្តាប់កត់ត្រា ហើយព្យាយាមទន្ទេញឱ្យចាំនូវអ្វីដែលគ្រូបានបង្រៀនសំរាប់ពេលប្រលង ដែលនាំឱ្យសិស្សមិនមានការរីកចំរើនទាល់តែសោះ។ ហើយខ្ញុំសង្ឃឹមថា យើងនឹងចាប់ផ្តើមនូវចំនុចបន្តិចម្តងៗ ដើម្បីជំរុញឱ្យមានការសិក្សាបែបសិស្សមជ្ឈមណ្ឌលនេះ។ កុមារទាំងអស់ គឺមានទស្សនៈផ្ទាល់ៗខ្លួនរបស់គេ ហើយគេនឹងបញ្ចេញ នូវទស្សនៈអំពីភាពលំបាករបស់គេផងដែរ កាលណាមានដំណោះស្រាយចេញពីអ្នកអប់រំ ពេលនោះគេនឹងមានជំនាញក្នុងការសិក្សាពិតប្រាកដ។ ដំណើរការសំខាន់ទៅអនាគតនោះ គឺថាតើយើងឱ្យកុមារមានដំណើរការរៀនដោយខ្លួនឯងតាមវិធីសាស្ត្រណា? ប៉ុន្តែវាអាស្រ័យទៅលើយើងយល់ពីតំរូវការរបស់កុមារ ហើយនិងពីរបៀបនៃការថែទាំកុមារ ហើយថាតើយើងត្រូវថែទាំកុមារឱ្យមានបំនិនជីវិតដូចម្តេច? ហើយយើងនឹងរៀបចំគេ ធ្វើសមាហរណកម្មគេចូលក្នុងសហគមន៍នៅក្នុងពិភពលោកដោយរបៀបណា?»។



«សិក្ខាកាមក្នុងសិក្ខាសាលាស្តីពីការរៀនបែបសិស្សមជ្ឈមណ្ឌល»

ជាទីបញ្ចប់ លោក Kevin Morley មានប្រសាសន៍ថា «សិក្ខាសាលាអស់រយៈពេល២ថ្ងៃមកនេះ អ្នកទាំងអស់គ្នាបានដឹងអំពីរបៀបការពារកុមារ ដឹងពីទិសដែលត្រូវទៅរបស់កុមារ ចិត្តសាស្ត្រ វិធីសាស្ត្រនៃការបង្រៀន និងការរៀនយុទ្ធសាស្ត្រនៃការរៀន ការអប់រំជាលក្ខណៈបុគ្គលដល់កុមារក្នុងការថែទាំសុខភាព។ ខ្ញុំសំណូមពរឱ្យអ្នកទាំងអស់គ្នាសួរខ្លួនឯងថាតើខ្ញុំបានធ្វើការងារនេះត្រឹមត្រូវទេ បានប្រសើរទេ? តើយើងអាចធ្វើការងារនេះឱ្យបានប្រសើរទេ? តើយើងត្រូវធ្វើអ្វីខ្លះ? ប្រសិនបើអ្នកដឹងថា អ្នកអាចធ្វើវាឱ្យប្រសើរបាន សូមធ្វើចុះ!»។ UWC នឹងបន្តផ្តល់ការបណ្តុះបណ្តាលដល់សមាជិកគ.អ.ស.កក្នុងជំនាញផ្សេងៗទៀតប្រសិនបើត្រូវការ៕

# សិក្ខាសាលាបណ្ដុះបណ្ដាលអ្នកអប់រំបន្តស្ដីពីការបញ្ជ្រាបការចូលរួមរបស់កុមារ



លោក ជា ពីដែន ថ្លែងសន្ទរកថា នាឱកាសបើកអង្គសិក្ខាសាលា

សិក្ខាសាលាបណ្ដុះបណ្ដាលអ្នកអប់រំបន្តស្ដីពីការបញ្ជ្រាបការចូលរួមរបស់កុមារ ជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកំពស់ចំណេះដឹងដល់អង្គការសមាជិក និងបុគ្គលិករបស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(គ.អ.ស.ក) ស្ដីពីការចូលរួមរបស់កុមារ ក៏ដូចជាការលើកកំពស់ការចូលរួមរបស់កុមារនៅក្នុងប្រទេសកម្ពុជា។

សិក្ខាសាលានេះរៀបចំឡើងដោយគ.អ.ស.ក កាលពីថ្ងៃទី៨_១០ ខែកុម្ភៈ ឆ្នាំ២០០៦ នៅអគ្គលេខាធិការដ្ឋាន គ.អ.ស.ក ដោយមានសិក្ខាកាមមកពីអង្គការសមាជិក និងបុគ្គលិកគ.អ.ស.ក ចូលរួមចំនួន២៧នាក់ និងតំណាងមកពីអង្គការ Child Worker in Asia (CWA) មួយនាក់។ សិក្ខាសាលានេះប្រារព្ធឡើងក្រោមជំនួយបច្ចេកទេស និងថវិការបស់អង្គការ Child Worker in Asia។

**លោក ជា ពីដែន** ប្រធានគ.អ.ស.ក មានប្រសាសន៍ក្នុងពិធីប្រកាសបើកអង្គសិក្ខាសាលានោះថា «សិក្ខាសាលានេះ ជាសិក្ខាសាលាមួយដែលសាកល្បងលើការអនុត្តន៍សៀវភៅណែនាំស្ដីពីការបញ្ជ្រាបការចូលរួមរបស់កុមារ ហើយសៀវភៅនេះ កើតចេញពីសិក្ខាសាលាថ្នាក់តំបន់ចំនួនពីរ ដែលបានរៀបចំឡើងក្នុងឆ្នាំ២០០៥ នៅទីក្រុងបាងកក ប្រទេសថៃ និងទីក្រុងកាតម៉ាន់ឌូ ប្រទេសនេប៉ាល់ ដែលកម្ពុជាយើងបានចូលរួមផងដែរ។ ថ្ងៃនេះ តំណាងគ.អ.ស.កដែលបានទៅចូលរួមនៅក្នុងសិក្ខាសាលានោះរួមមាន **លោក ម៉ិច សុខា និង លោក ស៊ុំ ចំរុង** នឹងចែករំលែកនូវចំណេះដឹងទាំងនោះដល់អង្គការសមាជិក»។

លោកបន្តទៀតថា «ខ្ញុំសង្ឃឹមថា សិក្ខាសាលាបីថ្ងៃនេះនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងបេសកកម្មដែលបង្កើនសមត្ថភាពដល់អង្គការសមាជិក ហើយលោក លោកស្រី នាងកញ្ញានឹងក្លាយជាអ្នកអប់រំបន្តដើម្បីបណ្ដុះបណ្ដាល និងផ្សព្វផ្សាយពីចំណេះដឹងស្ដីពីការចូលរួមរបស់កុមារ និងការបញ្ជ្រាបការចូលរួមរបស់កុមារទៅក្នុងកម្មវិធីការងារ»។

មុននឹងបញ្ចប់ លោកសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់កញ្ញា You Yun តំណាង CWA ដែលបានផ្ដល់ជំនួយថវិកា ព្រមទាំងចូលរួមចំណែកបណ្ដុះបណ្ដាលដល់អង្គការសមាជិក និងបុគ្គលិករបស់គ.អ.ស.ក។ ឆ្លៀតក្នុងឱកាសនោះ គ.អ.ស.កក៏បានប្រគល់វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាដល់សិក្ខាកាមផងដែរ៕

# គ្រឿងញៀនជាជំងឺរបស់សង្គមជាតិ

បច្ចុប្បន្នប្រទេសកម្ពុជាកំពុងជួបបញ្ហាជាច្រើនដែលធ្វើឱ្យប្រទេសនេះរាំងស្ទះ និងយឺតយ៉ាវក្នុងការអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលឱ្យកាន់តែរីកចំរើនថែមទៀតនោះ។ ស្របពេលនេះ បើយើងចោលចក្ខុទៅមើលក្រុមយុវជន យុវនារីមួយចំនួនដែលកំពុងភ្លើតភ្លើនក្នុងភាពជាយុវវ័យ បណ្ដោយខ្លួនរហូតហួសព្រំដែនឈានដល់ការប្រើប្រាស់គ្រឿងញៀន និងប្រព្រឹត្តបទល្មើសផ្សេងៗ ដែលជះឥទ្ធិពលអាក្រក់ជាច្រើនដល់ខ្លួនឯងផ្ទាល់ គ្រួសារ និងសង្គមជាតិ។

គ្រឿងញៀនជា បញ្ហាសំខាន់ដែលយើងទាំងអស់គ្នាចាំបាច់ត្រូវចាប់អារម្មណ៍ និងយកចិត្តទុកដាក់អំពីមូលហេតុដែលឈានដល់ការប្រើប្រាស់។ ទីកន្លែងប្រើប្រាស់ និងការជួញដូរគ្រឿងញៀន ផលអាក្រក់នៃការប្រើប្រាស់គ្រឿងញៀន នឹងត្រូវបានស្វែងរកដំណោះស្រាយដើម្បីកាត់បន្ថយរហូតឈានដល់ការលុបបំបាត់អ្នកប្រើប្រាស់ និងអ្នកជួញដូរគ្រឿងញៀន។

បើតាមការសង្កេតមើលសង្គមសព្វថ្ងៃ មូលហេតុធ្វើឱ្យយុវវ័យប្រើប្រាស់គ្រឿងញៀនច្រើន គឺដោយសារការដើរលេងភ្លើតភ្លើន សេពគប់មិត្តភក្តិមិនល្អ ការចង់សាកល្បង និងការចង់បញ្ជាក់ថាខ្លួនជាមនុស្សពេញវ័យ ដែលអាចមើលការខុសត្រូវ

តទៅទំព័រទី៩

# មណ្ឌលថ្ងៃល្អ







*កុមារកំពុងតែរៀនជំនាញនៅក្នុងមណ្ឌល*

«**មណ្ឌលថ្ងៃល្អ**» ជាជំរកបណ្ដោះអាសន្នរបស់កុមារ ដែលរងនូវការរំលោភបំពានគ្រប់រូបភាព និងកុមារក្រីក្រ ហើយជាកន្លែងដែលផ្ដល់នូវចំណេះ និងជំនាញផ្សេងៗ។ មណ្ឌលនេះត្រូវបានបង្កើតឡើងដោយ**មជ្ឈមណ្ឌលថែទាំសុខភាពកុមារ** (HCC) ហើយសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥។

**លោក ថែន សារឿន** ប្រធានមណ្ឌលថ្ងៃល្អ មានប្រសាសន៍ថា សព្វថ្ងៃមានកុមារីចំនួន៥៧នាក់ កំពុងស្នាក់នៅក្នុងមណ្ឌល ដែលកុមារខ្លះកំពុងរៀននៅសាលាចំណេះទូទៅ និងខ្លះកំពុងរៀនជំនាញ។ លោកបន្តថា ប្រភេទកុមារដែលត្រូវបានជ្រើសរើសឱ្យចូលស្នាក់នៅមណ្ឌល មានអាយុពី១០ដល់១៧ឆ្នាំ មាន៦ប្រភេទគឺ ១.កុមាររងការជួញដូរផ្លូវភេទ និងពលកម្មកុមារ ២.កុមាររងនូវការរំលោភសេពសន្ថវៈ ៣.កុមារប្រើថ្នាំញៀន ៤.កុមារដែលរស់នៅក្នុងគ្រួសារដែលប្រើអំពើហិង្សា ៥.កុមារកំព្រា ជាពិសេសកុមារកំព្រាដោយសារឪពុកម្ដាយស្លាប់ដោយសារជំងឺអេដស៍ និង៦.កុមារមានជីវភាពក្រីក្រ។

លោកបន្តទៀតថា កុមារដែលមានអាយុពី១០ទៅដល់១៦ឆ្នាំត្រូវបានបញ្ជូនឱ្យទៅរៀននៅសាលារដ្ឋ ហើយដល់គេអាយុ១៧ឆ្នាំ គេអាចរៀនជំនាញបំនិនជីវិត ឬកសិកម្មជាលក្ខណៈគ្រួសារ។ ចំពោះការបណ្ដុះបណ្ដាលជំនាញមានដូចជា កាត់ដេរម៉ូដ តម្បាញក្រមា ដេរកាបូប អ៊ុតសក់ និងហាត់ធាក់ម៉ាស៊ីនយន្ត។ ការរៀនជំនាញនេះត្រូវប្រើរយៈពេលពី៤ទៅ៦ខែ លើកលែងតែជំនាញហាត់ធាក់ម៉ាស៊ីនយន្តប្រើពេលតែ១ទៅ២សប្ដាហ៍ប៉ុណ្ណោះ។ លោកបន្តថា ជំនាញហាត់ធាក់ម៉ាស៊ីនយន្ត ងាយស្រួលរកការងារធ្វើនៅក្នុងរោងចក្រ។

**អ្នកគ្រូ អ៊ុន ស៊ីនមន** ជាគ្រូតម្បាញក្រមា បានឱ្យដឹងថា ការរៀនតម្បាញនេះកុមារប្រភេទណាក៏រៀនបានដែរ ឱ្យតែគេចង់រៀន ហើយផលិតផលដែលផលិតបាន គឺយកទៅបោះឱ្យម៉ូយនៅផ្សារ ហើយកុមារទទួលបានភាគរយពីអ្វីដែលគេបានធ្វើដោយទូទាត់ទៅនឹងវត្ថុធាតុដើម។

ចំណែកឯ**អ្នកគ្រូ អ៊ែល ស៊ីថា** ជាគ្រូដេរម៉ូដ មានប្រសាសន៍ថា កុមារដែលអាចរៀនដេរម៉ូដបានលុះត្រាតែគេបានរៀនអក្សរខ្លះ និងចេះចែកលេខផង។ ហើយនៅពេលបង្រៀនក៏មានការពិបាកខ្លះដែរ ព្រោះកុមារភាគច្រើនខ្វះខាតនូវចំណេះដឹង ដូច្នេះចំពោះកុមារណាដែលចង់រៀនមុខជំនាញនេះ ត្រូវបំប៉នអក្សរខ្មែរ ជាពិសេសគឺការគណនាលេខជាមុនសិន។

**កុមារី គង ចន្ថា** អាយុ១៦ឆ្នាំ ជាកុមារកំព្រា មកពីខេត្តកោះកុង និយាយថា «ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ នៅពេលដែលបានមកនៅក្នុងមណ្ឌលថ្ងៃល្អនេះ ព្រោះខ្ញុំបានទៅរៀន ហើយពេលទំនេរអាចមានឱកាសរៀនជំនាញ ដឹងអំពីសិទ្ធិកុមារ និងយល់ដឹងច្រើនអំពីការទប់ស្កាត់នូវការរំលោភបំពានផ្សេងៗមកលើកុមារ»។ នាងប្រាប់ថា នាងបានឆ្លៀតរៀនត្បាញក្រមាក្រៅម៉ោងសិក្សានៅសាលា ហើយទៅថ្ងៃអនាគតនាងចង់ធ្វើជាគ្រូបង្រៀន ព្រោះចូលចិត្តតាំងពីតូចក្នុងការពន្យល់ និងបង្រៀនគេ។ ជាចុងក្រោយ ចន្ថាសូមសំណូមពរដល់រដ្ឋាភិបាល និងអង្គការ ជួយទប់ស្កាត់អំពើរំលោភបំពានលើកុមារ និងសូមឱ្យកុមារខ្លួនឯងផ្ទាល់ ក្លាហាន តស៊ូដើម្បីជីវភាពទៅថ្ងៃអនាគត។

រីឯ**កុមារី ម៉ៃ ស្រីខុន** អាយុ១៤ឆ្នាំ មកពីក្រុងព្រះសីហនុ។ នាងជាកុមារដែលរស់នៅក្នុងជីវភាពក្រីក្រ ហើយត្រូវបងស្រីជីដូនមួយសុំឱ្យទៅនៅឯខេត្តកោះកុងជាមួយ ដើម្បីឱ្យជួយធ្វើកិច្ចការផ្ទះ និងមើលក្មួយ ព្រមទាំងទទួលនូវការវាយធ្វើបាបយ៉ាងខ្លាំង ហើយនាងទ្រាំមិនបានក៏លួចរត់ចេញពីទីនោះរហូតបានមកស្នាក់នៅក្នុងមណ្ឌលថ្ងៃល្អនេះ។ ស្រីខុន និយាយថា «ខ្ញុំមានអារម្មណ៍ថាស្រួលជាងមុន ហើយសប្បាយ ព្រោះបានរៀន ដឹងអំពីសិទ្ធិកុមារ និងបានទទួលនូវការណែនាំល្អៗ»។ នាងប្រាប់ថា នាងបានស្នាក់នៅមណ្ឌលរយៈពេលប្រហែលជា៣ខែមកហើយ ហើយសព្វថ្ងៃនាងកំពុងរៀននៅសាលារដ្ឋថ្នាក់ទី៦។ មុននឹងបញ្ចប់នាងសូមអរគុណចំពោះអង្គការដែលបានជួយនាង និងសូមឱ្យជួយដល់កុមារដែលគ្មានលទ្ធភាពឱ្យបានចូលរៀនផង។

ចំណែកសំដីរបស់កុមារី **កែម ស្រីថន** អាយុ១៣ឆ្នាំវិញនិយាយថា «ដោយសារតែជីវភាពក្រីក្រ រកបានព្រឹកខ្វះល្ងាចក៏មកសុំអង្គការស្នាក់នៅ និងរៀនជំនាញកាត់ដេរ ហើយទៅថ្ងៃអនាគត ខ្ញុំចង់ធ្វើជាជាងកាត់ដេរមួយរូប ដើម្បីជួយដល់ជីវភាពគ្រួសារខ្ញុំ។ ជាចុងក្រោយ ខ្ញុំសូមសំណូមពរឱ្យអង្គការជួយដល់កុមារក្រីក្រ ហើយកុមារត្រូវខិតខំរៀនសូត្រ»។

ជាទីបញ្ចប់ **លោក ទ៊ែន សារឿន** សូមសំណូមពរដល់រដ្ឋាភិបាលជួយទប់ស្កាត់ និងការពារកុមារឱ្យរួចផុតពីការរំលោភបំពានគ្រប់ប្រភេទ ហើយសូមបង្កើតច្បាប់ដើម្បីការពារកុមារឱ្យបានកាន់តែខ្លាំងក្លាថែមទៀត។ លើសពីនេះទៀត សូមពង្រឹងអ្នកអនុវត្តច្បាប់ឱ្យមានភាពប្រសើរឡើង ហើយសូមជួយយកចិត្តទុកដាក់ដល់ឧត្តមប្រយោជន៍របស់កុមារដើម្បីឱ្យស្របទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ ចំពោះអង្គការសង្គមស៊ីវិល សូមសហប្រតិបត្តិការឱ្យបានស្អិតរមួតក្នុងទិសដៅដែលជាអត្ថប្រយោជន៍រួមរបស់កុមារ៕

# មណ្ឌលចិញ្ចឹមកុមារដែលមានអាយុចាប់ពី១ថ្ងៃរហូតដល់១៨ឆ្នាំ

*មានបន្ទប់មួយដែលមានផ្លាក២ផ្ទាំង ផ្ទាំងទីមួយមានអត្ថន័យថា «សូមមេត្តាជួយជាវសមិទ្ធផលស្នាដៃផ្ទាល់របស់កុមារគឺជាការចូលរួមចំណែកជួយ និងលើកទឹកចិត្តដល់កុមារកំព្រា» និងផ្លាកទីពីថា «អាគារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ» តើបន្ទប់នេះជាអ្វី? នៅឯណា?*

*បន្ទប់នេះ ជាបន្ទប់ដែលមានផ្ទាំងរូបភាពដ៏ស្រស់ស្អាតដាក់តាំងតាមជញ្ជាំងជាច្រើនផ្ទាំង ព្រមទាំងមានកុមារតូចៗកំពុងអង្គុយផ្តង់អារម្មណ៍គូររូបយ៉ាងស្ងៀមស្ងាត់។ ទីនេះគឺជា «**សមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា**» ហៅកាត់ថាSFODA ដែលផ្តល់នូវការស្នាក់នៅរយៈពេលវែង និងជំនាញផ្សេងៗ។*

**លោក ប៉ែន សុផាន** នាយកប្រតិបត្តិនៃសមាគមអភិវឌ្ឍន៍គ្រួសារពលី និងកុមារកំព្រា មានប្រសាសន៍ថា បច្ចុប្បន្ននេះ មានកុមារនៅក្នុងមណ្ឌលចំនួន៦៧នាក់ ក្នុងនោះមានកុមារីចំនួន២២នាក់ កុមារទាំងនោះមកពីគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា។

លោកបន្តថា កុមារដែលត្រូវបានជ្រើសរើសឱ្យស្នាក់នៅមណ្ឌល គឺ៨០ភាគរយជាកុមារដែលទទួលផលប៉ះពាល់ដោយសារមេរោគអេដស៍ និង២០ភាគរយជាកុមាររងនូវករណីផ្សេងៗ។ កុមារទាំងនេះមានអាយុចាប់ពី១ថ្ងៃ ដល់១៨ឆ្នាំ។

រីឯការបណ្តុះបណ្តាលជំនាញវិញ លោកបានឱ្យដឹងទៀតថា នៅមណ្ឌលរបស់លោកមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចំនួន៣ គឺគូររូបភាព ច្នៃត្បូង និងឆ្លាក់ស្ពាន់ និងប្រាក់។ ជំនាញទាំងនេះត្រូវចំណាយពេលពី១ឆ្នាំទៅ២ឆ្នាំ។

លោកមានប្រសាសន៍ទៀតថា កុមារទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីសមាគមដូចជា ទទួលបាននូវជំរកសមរម្យ ចូលរៀននៅសាសារដ្ឋ រៀនជំនាញ មានឪពុកម្តាយធម៌នៅក្រៅប្រទេស ហើយក្រោយពេលដែលពួកគេរៀនចប់ ចេះនូវជំនាញស្ទាត់ សមាគមជួយរកទីកន្លែងប្រកបការងារ និងផ្តល់ជាដើមទុន។ល។ សព្វថ្ងៃនេះ កុមារនៅក្នុងមណ្ឌលភាគច្រើនមានឪពុកម្តាយធម៌ស្ទើតែទាំងអស់ទៅហើយ។

យុវជន **អៀង សំណាង** អាយុ១៩ឆ្នាំ ជាកុមារកំព្រា មានបងប្អូន២នាក់កំពុងស្នាក់នៅក្នុងមណ្ឌល ហើយក៏ជាគ្រូបង្រៀនផ្នែកគំនូរមួយរូប និយាយថា «ខ្ញុំបានបង្រៀនផ្នែកគូរគំនូរនេះរយៈពេលប្រហែលជា៧ខែមកហើយ ហើយសិស្សដែលបានរៀនជាមួយខ្ញុំមានប្រហែលជា២០នាក់»។ ប្អូនប្រុសប្រាប់ថា ការរៀនគូរគំនូរនេះមិនមានការពិបាកអ្វីទេបើយើងចូលចិត្ត។

ចំណែកឯ**កុមារា ចាន់ ម៉ាឌី** អាយុ១៣ឆ្នាំ កុមារកំព្រាមានបងប្អូន៣នាក់ មកពីអ្នកលឿង និយាយថា «ខ្ញុំសប្បាយណាស់ដែលបាននៅមណ្ឌល ព្រោះគេបានផ្តល់នូវចំណេះដឹងឱ្យ។ សព្វថ្ងៃខ្ញុំកំពុងរៀននៅសាលាជ្រោយចង្វាថ្នាក់ទី៤ ព្រមទាំងរៀនគូរគំនូរនៅក្នុងមណ្ឌល»។ ម៉ាឌីប្រាប់ថា គេធ្លាប់ទៅចូលរួមប្រលងគំនូរនៅNGOCRC កាលពីឆ្នាំ២០០៥ ហើយទទួលបានចំណាត់ថ្នាក់លេខ២ផងដែរ។

ចំពោះ **កុមារី រ័ត្ន ស្រីល័ក្ខ** អាយុ១៣ឆ្នាំ មានបងប្អូន២នាក់ ដែលបងប្រុសនាងក៏ស្នាក់នៅក្នុងមណ្ឌលនេះដែរ ប្រាប់ថា នាងជាកុមារកំព្រា មកនៅក្នុងមណ្ឌលតាំងពីអាយុប្រហែល៧ឆ្នាំមកម្លេះ។ នាងនិយាយថា «ខ្ញុំមានអារម្មណ៍រីករាយណាស់ដែលបានមកនៅក្នុងមណ្ឌល ព្រោះបានជួបជុំបងប្អូន និងបានរៀន»។ នាងប្រាប់ទៀតថា «ខ្ញុំសព្វថ្ងៃកំពុងរៀននៅសាលាជ្រោយចង្វាថ្នាក់ទី៦ និងរៀនគូររូបនៅក្នុងមណ្ឌល ៣ឆ្នាំហើយ»។ នាងបន្តថា «ខ្ញុំមានឪពុកម្តាយធម៌នៅស្រុកបារាំងរយៈពេល៣ឆ្នាំហើយ គេតែងតែជួយនូវសំភារៈសិក្សា និងសំលៀកបំពាក់ដល់ខ្ញុំ។ ទៅថ្ងៃអនាគតខ្ញុំចង់ធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស និងអក្សរខ្មែរ។»

រីឯ**កុមារា សុខ ជា** អាយុ១៧ឆ្នាំ ជាកុមារកំព្រា មកពីខេត្តបាត់ដំបង រៀនថ្នាក់ទី៩ និងសព្វថ្ងៃក្លាយជាគ្រូបង្រៀនផ្នែកច្នៃត្បូង និយាយថា «ខ្ញុំមានអារម្មណ៍សប្បាយដែលបានស្នាក់នៅក្នុងមណ្ឌល ព្រោះបានរៀនសូត្រគ្រប់គ្រាន់ មានទំនុកចិត្តក្នុងការងារ និងការសិក្សា»។ ប្អូនប្រាប់ថា «ការរៀនច្នៃត្បូងនេះមានការពិបាក ដូច្នេះសិស្សត្រូវមានការតស៊ូ និងអំណត់បំផុត ប៉ុន្តែមានទីផ្សារល្អ»។ ទៅថ្ងៃអនាគតប្អូនប្រាប់ថា ចង់បើកហាងច្នៃត្បូងមួយកន្លែង។

នេះជាសំដីរបស់**កុមារា សុខ មេសា** អាយុ១៥ឆ្នាំ ថា «ការរស់នៅជាមួយពូ និងនៅមណ្ឌលគឺខុសគ្នា ព្រោះនៅមណ្ឌលបានរៀនសូត្រ ហើយរៀនជំនាញទៀត។ ខ្ញុំរៀនច្នៃត្បូង២ឆ្នាំហើយ វាជាជំនាញល្អមានទីផ្សារ ធ្វើភ្លាម បានលុយភ្លាម»។ ប្អូនប្រុសប្រាប់ថា សព្វថ្ងៃប្អូនរៀនថ្នាក់ទី៨ រស់នៅក្នុងមណ្ឌលរយៈពេល៧ឆ្នាំហើយ។ ចំណែកឯបំណងទៅថ្ងៃអនាគត ប្អូនចង់ធ្វើជាគ្រូពេទ្យដើម្បីជួយដល់អ្នកក្រីក្រ។

ជាចុងក្រោយ **កុមារា ផាន វីសូ** អាយុ១៣ឆ្នាំ កុមារកំព្រា មកពីខេត្តកំពង់ឆ្នាំង កំពុងរៀនថ្នាក់ទី៤នៅសាលាជ្រោយចង្វា និយាយថា «បើប្រៀបធៀបការរស់នៅជាមួយអ៊ំ និងនៅ




*កុមារកំពុងតែរៀនគូសរូប*



*កុមារកំពុងតែរៀនច្នៃត្បូង*



*កុមារកំពុងតែរៀនឆ្លាក់ស្ពាន់ និងប្រាក់*

មណ្ឌលខ្ញុំគិតថា នៅមណ្ឌលល្អជាង ព្រោះបានរៀន គេអប់រំល្អ មិនឱ្យដើរលេងតាមចិញ្ចើមថ្នល់ ជក់ម៉ា និងឱ្យខំរៀន។ ម្យ៉ាងទៀត ខ្ញុំមានឪពុកម្តាយធម៌ជួយសំភារៈផ្សេងៗ និងទិញកង់ឱ្យជិះទៅរៀន»។ ប្អូនបន្តថា «ទៅអនាគតខ្ញុំចង់ធ្វើជាគ្រូចំលាក់ ព្រោះឥឡូវខ្ញុំកំពុងរៀនផ្នែកឆ្លាក់ស្ពាន់ បានរយៈពេល៣ខែ ហើយចេះបាន៣ក្បាច់»៕

# មន្ត្រីសុខាភិបាលជាអ្នកជួបមុខកុមារមុនគេបំផុត

បើយើងពិនិត្យមើលនៅក្នុងសង្គមសព្វថ្ងៃ អ្នកដែលជួបកុមារមុនដំបូងគេបំផុតចាប់តាំងពីចាប់កំណើតក្នុងផ្ទៃម្តាយរហូតដល់ពេលកើត និងក្រោយពេលកើតមកនោះ គឺមន្ត្រីសុខាភិបាល ពិសេសគឺពេទ្យឆ្មប។ ដូចនេះផ្នែកសុខាភិបាលគឺ មានតួនាទីយ៉ាងសំខាន់បំផុត ក្នុងការធ្វើឱ្យកុមាររស់រានមានជីវិតប្រកបដោយសុខមាលភាព។

ដើម្បីធ្វើឱ្យសេវាផ្នែកសុខភាពចំពោះកុមារកាន់តែមានប្រសិទ្ធិភាព ឆ្លើយតបចំពោះមាត្រា២៤នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនោះ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) បានជ្រើសរើសយកមន្ត្រីសុខាភិបាលជាក្រុមគោលដៅមួយ ដែលសំខាន់សំរាប់ធ្វើការបញ្ជ្រាបការយល់ដឹងផ្នែកសិទ្ធិកុមារ ទៅក្នុងសកម្មភាពការងារប្រចាំថ្ងៃរបស់ពួកគេ។

នេះជាលើកទី៥ហើយ ដែលគ.អ.ស.ករៀបចំសិក្ខាសាលាស្តីពីការលើកកំពស់ការយល់ដឹងស្តីពីការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដល់មន្ត្រីសុខាភិបាល។ សិក្ខាសាលាត្រូវបានប្រារព្ធធ្វើកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ មានរយៈពេលបីថ្ងៃ ដោយមានសិក្ខាកាមចូលរួមចំនួន៣០នាក់ មកពីតំបន់ប្រតិបត្តិទាំងបួននៅរាជធានីភ្នំពេញ ក្រោមជំនួយឧបត្ថមរបស់អង្គការន័រវេស្ស៍សង្គ្រោះកុមារ។

**លោក ជា ពីដែន** ប្រធានគ.អ.ស.ក មានប្រសាសន៍ក្នុងពិធីប្រកាសបើកអង្គសិក្ខាសាលានោះថា “សិក្ខាសាលាថ្ងៃនេះផ្តោតលើការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារចំពោះមន្ត្រីសុខាភិបាល គឺមានន័យថាកុមារគ្រប់រូបទទួលបានសិទ្ធិជាមូលដ្ឋាន តាមរយៈមន្ត្រីសុខាភិបាល ហើយសិក្ខាសាលារយៈពេលបីថ្ងៃនេះ យើងនឹងជជែករកឃើញនូវគន្លឹះជាច្រើនពាក់ព័ន្ធនឹងកុមារ ហើយយើងនឹងបន្តដោះស្រាយនូវបញ្ហាកុមារនៅប្រទេសយើង ជាពិសេសកុមារដែលមកពីគ្រួសារយ៉ាប់យឺនទាំងឡាយ ដើម្បីទទួលបាននូវការព្យាបាលឱ្យសមស្រប ដូចអ្នកដែលមានជីវភាពធូរធារ និងរស់នៅឱ្យបានត្រឹមត្រូវ ជាពិសេសអ្នកនៅទីក្រុង ហើយនិងកុមារដទៃទៀតនៅតាម



ពិធីប្រគល់វិញ្ញាបនប័ត្រដល់សិក្ខាកាម

តំបន់ដាច់ស្រយាល។ ខ្ញុំសង្ឃឹមថាចំណេះដឹងទាំងអស់នេះ និងបទពិសោធន៍របស់លោក លោកស្រី ដែលមានកន្លងមក នឹងផ្សព្វផ្សាយបន្តទៅអ្នកដែលមិនទាន់បានយកទៅប្រើផ្ទាល់សំរាប់កុមារ។ ម្យ៉ាងទៀត គឺថា វិស័យសុខាភិបាលនៅក្នុងប្រទេសកម្ពុជាជារឿងមួយសំខាន់ ដែលយើងទាំងអស់គ្នាត្រូវរួមគ្នាធ្វើដោយមិនចាំបាច់តែមន្ត្រីសុខាភិបាលតែឯងទេ គឺមានស្ថាប័ន និងមន្ទីរដែលពាក់ព័ន្ធទាំងអស់ ហើយនិងមនុស្សទាំងអស់ ជាពិសេសគឺ សហគមន៍ត្រូវរួមសហការគ្នាក្នុងការជួយដល់កុមារ”។

នៅក្នុងសិក្ខាសាលានោះដែរ សិក្ខាកាមបានកំណត់ផែនការសកម្មភាពមួយចំនួនដែលត្រូវដាក់បញ្ចូលបន្ថែមទៅក្នុងការងារប្រចាំថ្ងៃក្រោយពេលដែលពួកគាត់ត្រឡប់ទៅវិញ រួមមាន៖ ១.បន្ថែមសកម្មភាពអប់រំពីបញ្ហាសុខភាពកុមារដោយបង្កើនពេលវេលាច្រើនមុន។ ២.បន្ថែមការអនុគ្រោះទាំងពេលវេលា និងថវិកាដល់កុមារក្រីក្រ កុមារកំព្រា និងកុមារមានជំងឺធ្ងន់ធ្ងរ។ ៣.រៀបចំបន្ទប់អនាម័យ និងទឹកសំរាប់កុមារផឹក។ ៤. បន្ថែមឱសថសំរាប់កុមារឱ្យបានច្រើនជាងមនុស្សចាស់។ ៥. បន្ថែមបុគ្គលិកពេលចុះចាក់វ៉ាក់សាំង ងាយស្រួលក្នុងការពន្យល់ណែនាំដល់កុមារ និងអាណាព្យាបាល។ ៦.បន្ថែមបុគ្គលិកផ្នែកសម្ភពនៅមណ្ឌលសុខភាពជាយក្រុង។ ៧.បន្ថែមបុគ្គលិកផ្នែកចែកចាយឱសថ និងពង្រីកបន្ទប់ ដើម្បីបង្កើនភាពងាយស្រួលដល់កុមាររង់ចាំ និងងាយស្រួលរបៀបប្រើប្រាស់ (ឱសថដោយការពន្យល់ច្រើន)។ ៨.បន្ថែមគ្រូពេទ្យផ្នែកពិនិត្យជំងឺក្រៅ និង

តទៅទំព័រទី១១

តមកពីទំព័រទី៤

លើខ្លួនឯងបាន។ មូលហេតុមួយចំនួនទៀត គឺដោយសារតែមានបញ្ហាផ្លូវចិត្ត ទទួលបញ្ហាក្នុងគ្រួសារ ដូចជាឪពុកម្តាយចែកផ្លូវគ្នា មានអំពើហិង្សាក្នុងគ្រួសារ ឪពុកមានប្រពន្ធចុងដែលធ្វើឱ្យកើតមានជំលោះក្នុងគ្រួសារ ឬវិបត្តិស្នេហា។ ក្រុមយុវវ័យមួយចំនួនទៀតដែលប្រើប្រាស់គ្រឿងញៀន គឺបណ្តាលមកពីកង្វះខាតនូវការអប់រំ ការមិនយកចិត្តទុកដាក់ និងមិនបានផ្តល់ភាពកក់ក្តៅដល់កូនពីអាណាព្យាបាល។ អ្នកប្រើប្រាស់គ្រឿងញៀនមួយចំនួនទៀត គឺប្រើសំរាប់ជំនួយកំលាំងក្នុងការងារដូចជា កម្មករនេសាទ កម្មករលីសែងនៅទីប្រជុំជនប៉ោយប៉ែត និងបណ្តាកន្លែងផ្សេងៗទៀត។ ក្រុមយុវវ័យប្រើប្រាស់គ្រឿងញៀនភាគច្រើនជា សិស្សនិស្សិត កម្មករ ក្មេងអនាថា ស្រ្តីរកស៊ីផ្លូវភេទ ស្រ្តីលក់ស្រាបៀរ និងជនដែលគ្មានការងារធ្វើពិតប្រាកដ។

ការប្រើប្រាស់ និងជួញដូរគ្រឿងញៀននៅទីក្រុងភ្នំពេញក៏ដូចជាបណ្តាខេត្តនានាដែរ គឺភាគច្រើននៅកន្លែងស្រ្តីរកស៊ីផ្លូវភេទ បារ រង្គសាលរាត្រី ហាងខារ៉ាអូខេ ហាងម៉ាស្សា តាមផ្ទះសំណាក់មួយចំនួន ធ្វើឡើងសំរាប់បង្កលក្ខណៈងាយស្រួលដល់ក្រុមយុវវ័យជក់គ្រឿងញៀន នៅតាមសាលារៀន តំបន់សំណង់អាណាធិតេយ្យ ទីប្រជុំជន ជាពិសេស គឺនៅតំបន់ជាយដែនដែលជាកន្លែងប្រើប្រាស់ និងជួញដូរមានលក្ខណៈទ្រង់ទ្រាយធំ។

ការប្រើប្រាស់គ្រឿងញៀនមានគ្រប់រូបភាពរួមមាន ការចាក់តាមសរសៃ ជក់ លេប និងហិត។ អ្នកប្រើប្រាស់គ្រឿងញៀនកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរនៃការឆ្លងជំងឺអេដស៍ ហើយនឹងធ្វើឱ្យពួកគេបាត់បង់នូវការគិតពិចារណា និងភ្លេចអស់នូវមិត្តភក្តិ បងប្អូន ឪពុកម្តាយ បាត់បង់មនុស្សធម៌ក្នុងខ្លួន ប៉ះពាល់ដល់សុខភាព រាងកាយចុះថយកំលាំង បើប្រើដល់កំរិត អាចក្លាយទៅជាមនុស្សឡប់សតិ និងបាត់បង់ជីវិត ព្រមទាំងបំផ្លាញថវិកាទៅលើការទិញគ្រឿងញៀនជាច្រើនទៀតផង រហូតឈានទៅប្រព្រឹត្តបទល្មើសដោយមិនដឹងខ្លួន។ បើមានសមាជិកណាម្នាក់ក្នុងគ្រួសារប្រើប្រាស់គ្រឿងញៀន គ្រួសារដែលធ្លាប់តែមានភាពញញឹម និងសេចក្តីសុខនោះ នឹងប្រែក្លាយទៅជាគ្រួសារដែលមានទុក្ខលំបាកទាំងផ្លូវចិត្ត និងកាយ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ រហូតអាចឈានដល់ការបែកបាក់គ្រួសារថែមទៀត។

យោងតាមរបាយការណ៍របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបង្ហាញថា ក្នុងឆ្នាំ២០០៥ សមត្ថកិច្ចអនុវត្តច្បាប់បង្ក្រាបបានជនល្មើសចំនួន ៧០៩នាក់ មាន១៣២នាក់ទទួលការអប់រំ និង៥៧៧នាក់ត្រូវកាត់ទោស។ មានអ្នកប្រើគ្រឿងញៀនចំនួន៦.៨៧៦នាក់ ហើយតាមការប៉ាន់ស្មានចំនួនអ្នកប្រើគ្រឿងញៀនពិតប្រាកដ អាចស្មើនឹងចំនួនដែលរកឃើញនេះគុណនឹង៥ឬគុណនឹង១០ផង។ ព្រមទាំងមានវត្ថុតាងដែលរឹបអូសបានជាថ្នាំយ៉ាម៉ាចំនួន៣៣៨.៦៥៥គ្រាប់ ហេរ៉ូអ៊ីន១១,០៦គីឡូក្រាម កូកាអ៊ីន១គីឡូក្រាម កញ្ឆា១០២,៥០គីឡូក្រាម ដែលស្មើនឹង៣៦៦ករណី គឺកើនឡើង១៤៩ករណីបើប្រៀបធៀបទៅនឹងឆ្នាំ២០០៤ មានតែ២១៧ករណី មានជនល្មើស៤៨៩នាក់ និងអ្នកប្រើគ្រឿងញៀនមានចំនួន៥.៥០២នាក់ប៉ុណ្ណោះ នៅក្នុង១៥ខេត្តក្រុង។ ការប្រព្រឹត្តបទល្មើសនៃអ្នកប្រើប្រាស់គ្រឿងញៀន និងការកើនឡើងនៃការជួញដូរគ្រឿងញៀន គឺជាបញ្ហារបស់សង្គមជាតិយើង ដែលជាបន្ទុកដ៏ធ្ងន់ធ្ងររបស់រាជរដ្ឋាភិបាលត្រូវតែដោះស្រាយដើម្បីកាត់បន្ថយ និងឈានដល់ការលុបបំបាត់ចោលទាំងស្រុង។

រដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការដោះស្រាយនូវអ្នកប្រើប្រាស់គ្រឿងញៀនដោយបង្កើតនូវកន្លែងផ្តាច់ថ្នាំញៀនក្នុងបន្ទាយកងរាជអាវុធហត្ថនៅខេត្តបន្ទាយមានជ័យ និងបាត់ដំបងដែលកំពុងទទួលបានលទ្ធផលគួរឱ្យចាប់អារម្មណ៍ ហើយថែមទាំងបានបង្កើតអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងបានធ្វើការយ៉ាងជិតដិតជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែលកំពុងធ្វើការលុបបំបាត់ និងជួយដល់អ្នកដែលញៀនថ្នាំ។

ដើម្បីកាត់បន្ថយនូវបញ្ហាគ្រឿងញៀនរាជរដ្ឋាភិបាលគប្បី÷

- រឹតបន្តឹងការអនុវត្តន៍ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។
- មានយុទ្ធនាការដ៏ទូលំទូលាយដែលមានរយៈពេលវែងនៅទូទាំងប្រទេស ក្នុងការបង្ការ បង្ក្រាប និងលុបបំបាត់ការនាំចូល ការប្រើប្រាស់ ជួញដូរ និងផលិតគ្រឿងញៀន។
- បង្កើនថវិកាជាតិសំរាប់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន។
- បង្កើនមជ្ឈមណ្ឌលថែទាំ និងផ្តាច់គ្រឿងញៀនដល់ជនដែលរងគ្រោះដោយសារគ្រឿងញៀន៕

# ករណីរំលោភបំពានលើកុមារពីខែមករា ដល់ខែមីនា ឆ្នាំ២០០៦

នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០០៦ ប្រព័ន្ធគ្រប់គ្រងករណីរំលោភបំពានលើកុមាររបស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) បង្ហាញថា មានករណីចំនួន៥៤ករណី កើតឡើងលើកុមារ ដែលប្រមូលមកពីអង្គការសមាជិក និងកាសែតក្នុងស្រុក។

ករណីទាំងនោះរួមមាន៖

**១.** ទារុណកម្មលើរាងកាយចំនួន២ករណី កើតឡើងនៅភ្នំពេញ និងខេត្តស្វាយរៀង មានកុមាររងគ្រោះចំនួន២នាក់ អាយុចន្លោះ១០_១៤ឆ្នាំចំនួន១នាក់ អាយុពី១៥_១៧ឆ្នាំចំនួន១នាក់ និងជនល្មើសមានចំនួន១នាក់ អាយុចន្លោះពី៤៦ដល់៥២ឆ្នាំ។ ជនល្មើសម្នាក់ជាឪពុកចុង ម្នាក់ទៀតមិនត្រូវបានបញ្ជាក់។

**២.** បៀតបៀនកេរ្តិ៍ខ្មាស់ចំនួន១១ករណី ទីកន្លែងដែលកើតមានច្រើនជាងគេនៅខេត្តកំពង់ចាម និងភ្នំពេញ។ មានកុមាររងគ្រោះចំនួន១១នាក់ អាយុក្រោម១០ឆ្នាំចំនួន៥នាក់ អាយុពី១០_១៤ឆ្នាំចំនួន៥នាក់ អាយុពី១៥_១៧ចំនួន១នាក់។ ជនល្មើសមានចំនួន១០នាក់ អាយុពី១៨_២៤ឆ្នាំជាវ័យដែលប្រព្រឹត្តបទល្មើសច្រើនជាងគេ។ ករណីទាំងនេះកើតឡើង មូលហេតុមកពី កុមាររងគ្រោះនៅផ្ទះ ឬដើរលេងពេលយប់ម្នាក់ឯង ឆាប់ជឿពាក្យលួងលោមរបស់ជនល្មើស ដើរលេងពេលយប់ជាមួយជនល្មើស។ ជនល្មើសភាគច្រើនជាអ្នកស្គាល់គ្នា ដូចជាឪពុកចុង បងថ្លៃ អ្នកជិតខាង។ល។ ជនល្មើសដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នមានចំនួន៩នាក់ នៅក្រៅឃុំចំនួន១នាក់ និងមិនបានបញ្ជាក់ចំនួន១នាក់។

**៣.** ឃាតកម្ម ឬអត្តឃាតចំនួន២ករណី កើតឡើងនៅខេត្តកំពង់ស្ពឺ និងកោះកុង។ មានកុមាររងគ្រោះចំនួន២នាក់ អាយុក្រោម១០ឆ្នាំ ហើយជនល្មើសអាយុពី២៥_៣១ឆ្នាំចំនួន១នាក់ អាយុពី៣២_៣៨ឆ្នាំចំនួន១នាក់។ ករណីនេះ មិនបានបញ្ជាក់ពីមូលហេតុទេ ហើយជនរងគ្រោះជាក្មួយស្រីជនល្មើស។ ជនល្មើសត្រូវបានឃុំខ្លួនបណ្តោះអាសន្នចំនួន២នាក់។

**៤.** សំលាប់ក្រោយពីរំលោភសេពសន្ថវៈចំនួន៤ករណី កើតឡើងនៅខេត្តកំពង់ចាម៣ករណី និងខេត្តព្រះវិហារ១ករណី។ កុមាររងគ្រោះចំនួន៤នាក់ អាយុចន្លោះពី១០_១៤ឆ្នាំ។ មានជនល្មើសចំនួន១នាក់ អាយុចន្លោះពី១៨_២៤ឆ្នាំ ជាអ្នកភូមិជាមួយគ្នា ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន និង ៣នាក់ទៀតមិនបានបញ្ជាក់។ មូលហេតុមកពីជនរងគ្រោះម្នាក់ថា ទៅឃ្វាលគោតែម្នាក់ឯង ម្នាក់ទៀតថា ដើរលេងពេលយប់ម្នាក់ឯង ហើយ ២នាក់ទៀតមិនបានបញ្ជាក់ពីមូលហេតុ។

**៥.** រំលោភសេពសន្ថវៈចំនួន៣២ករណី កើតនៅខេត្តបាត់ដំបងចំនួន៦ករណី កំពង់ធំចំនួន៥ករណី កំពង់ចាមចំនួន៤ករណី បន្ទាយមានជ័យចំនួន៤ករណី ភ្នំពេញចំនួន៤ករណី ក្រចេះចំនួន២ករណី ស្វាយរៀងចំនួន២ករណី កណ្តាលចំនួន១ករណី ក្រុងព្រះសីហនុចំនួន១ករណី សៀមរាបចំនួន១ករណី តាកែវចំនួន១ករណី និង១ករណីនៅក្រៅប្រទេស។ មានកុមាររងគ្រោះចំនួន៣២នាក់ អាយុក្រោម១០ឆ្នាំចំនួន១៥នាក់ អាយុពី១០_១៤ឆ្នាំចំនួន១០នាក់ អាយុពី១៥_១៧ឆ្នាំចំនួន៧នាក់។ ជនល្មើសមានចំនួន២៩នាក់ ជនល្មើសដែលប្រព្រឹត្តបទល្មើសនេះច្រើនជាងគេគឺ អាយុពី១៨_២៤ឆ្នាំចំនួន ៤៤,៨២% អាយុពី១១_១៧ឆ្នាំចំនួន២៤,១៣% អាយុពី២៥_៣១ឆ្នាំចំនួន១០, ៣៤% អាយុពី៣៩_៤៥ឆ្នាំចំនួន ១០, ៣៤% អាយុពី៣២_៣៨ឆ្នាំចំនួន៣,៤៤% អាយុពី៤៦_៥២ឆ្នាំចំនួន៣,៤៤% អាយុពី៥៣_៥៩ឆ្នាំចំនួន



តទៅទំព័រទី១១

តមកពីទំព័រទី៨

ចំណេះដឹង។ ៩.បង្កើនបច្ចេកទេសដល់គ្រូពេទ្យកុមារ និងគិលានុបដ្ឋាយិកា ...

ចំណេះដឹង។ ៩.បង្កើនបច្ចេកទេសដល់គ្រូពេទ្យកុមារ និងឥរិយាបទ។ ១០.បង្កើនពេលម៉ោងយាមឱ្យបាន២៤ម៉ោងលើ២៤ម៉ោង។ ១១.បន្ថែមធុងអនាម័យ និងប្រអប់សុវត្ថិភាព។ ១២.បន្ថែមកៅអីរង់ចាំបង្កលក្ខណៈងាយស្រួលដល់កុមារ មានម្ជុលប់គ្រប់គ្រាន់ បំបាត់ឧបករណ៍ និងទីកន្លែងគ្រោះថ្នាក់។ ១៣.បន្ថែមរបងសុវត្ថិភាពជុំវិញមណ្ឌលសុខភាព។ ១៤.បន្ថែមកន្លែងកំសាន្តដល់កុមារ។ ១៥.ជួយបង្កើនការបញ្ជូនកុមារពេលមានជំងឺធ្ងន់ធ្ងរឱ្យបានអត្រាខ្ពស់។ ១៥.ជួយកាត់បន្ថយអត្រាគ្រោះថ្នាក់កុមារដោយសារជំនឿជ្រុលនិយម និងពាក្យចចាមអារាមពីជំងឺ និងការចាក់ថ្នាំបង្ការជំងឺរលាកស្រោមខួរ។ ១៦.ផ្តល់ការសំងាត់ដល់កុមារ។ និង១៧.បន្ថែមការផ្សព្វផ្សាយ និងអប់រំដល់សុខភាពកុមារ។

ជាទីបញ្ចប់ **លោក មាស សំណាង** អនុប្រធានគ.អ.ស.ក ថ្លែងសន្ទរកថាបិទអង្គសិក្ខាសាលា ដោយលោកបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោក វេជ្ជបណ្ឌិត មាស ឡុង** ដែលបានចំណាយពេលវេលាដ៏ធំធេងចូលរួមក្នុងសិក្ខាសាលាក្នុងការផ្តល់នូវចំណេះដឹងផ្នែកសិទ្ធិកុមារ ដែលទាក់ទងនឹងវិស័យសុខាភិបាល និងសូមថ្លែងអំណរគុណដល់សិក្ខាកាមទាំងអស់ដែលបានចំណាយពេលវេលា ឃ្លាតចាកឆ្ងាយពីអ្នកជំងឺដែលវត្តមានរបស់អ្នកទាំងអស់ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេសគ្រូពេទ្យដែលធ្វើការផ្ទាល់ជាមួយកុមារ ហើយសង្ឃឹមថា អ្វីដែលបានជជែកអស់រយៈពេល៣ថ្ងៃនេះ លោក លោកស្រី នាងកញ្ញា ពិតជាធ្វើឱ្យមានការខុសប្លែកក្នុងពេលបច្ចុប្បន្ន និងអនាគតកាល ជាពិសេសធ្វើយ៉ាងណាដើម្បីឱ្យ កុមារទទួលបាននូវការផ្តល់សេវាសុខភាពប្រកបដោយគុណភាព និងការយកចិត្តទុកដាក់ដោយលោក លោកស្រីដែលជាមន្ត្រីសុខាភិបាល។ ជាចុងក្រោយលោកសូមថ្លែងអំណរគុណចំពោះអង្គការសង្គ្រោះកុមារន័រវេស្ស៍ដែលបានផ្តល់ការឧបត្ថម្ភថវិកា ដើម្បីបង្កើតឱ្យមានកម្មវិធីវគ្គបណ្តុះបណ្តាល ទាំងវគ្គនេះក៏ដូចជាវគ្គកន្លងទៅ ហើយនិងវគ្គទៅអនាគតទៀតដោយទទួលបានដោយជោគជ័យ។

នៅខណៈនោះដែរ គ.អ.ស.កក៏បានប្រគល់វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាដល់សិក្ខាកាមចំនួន៣០នាក់ផងដែរ៕

តមកពីទំព័រទី១០

៣,៤៤%។ មានជនល្មើសចំនួន២៣នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ៣នាក់នៅក្រៅឃុំ ៣នាក់រត់គេចបាត់ និង៣នាក់មិនត្រូវបានបញ្ជាក់។ មូលហេតុមកពី កុមាររងគ្រោះនៅផ្ទះ ឬទៅឃ្វាលគោ ឬដើរពេលយប់ម្នាក់ឯង ទៅផ្ទះជនល្មើស ចាញ់បោកគេដោយសារឆាប់ជឿពាក្យលួងលោមគេ។ ចំណែកឯជនល្មើស សារភាពថា មកពីគេស្រវឹងស្រា ខ្លះថាមើលរឿងស៊ិច។ ជនល្មើសភាគច្រើនជាអ្នកភូមិជាមួយគ្នា អ្នកជិតខាង ឪពុក អ៊ំ សង្ឃា ពូ ចៅកែ។ល។ ជនល្មើសតែងតែគំរាមពេលប្រព្រឹត្តបទល្មើសថា សំលាប់ចោល ឬប្រើកាំភ្លើងគំរាម។

**៦.** ជួញដូរចំនួន៣ករណី កើតឡើងនៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង និងតាកែវ។ មានកុមាររងគ្រោះចំនួន៤នាក់ អាយុក្រោម១០ឆ្នាំចំនួន១ នាក់ អាយុពី១០_១៤ចំនួន១នាក់ អាយុពី១៥_១៧ ចំនួន២នាក់។ ជនល្មើសមានចំនួន៣នាក់ អាយុពី២៥_៣១ចំនួន១នាក់ អាយុពី៣២_៣៨ចំនួន១នាក់ អាយុពី៥៣_៥៩ចំនួន១នាក់ ជនល្មើសត្រូវជាអ្នកភូមិជាមួយគ្នា ខ្លះមិនស្គាល់។ មានជនល្មើស៣នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ មូលហេតុម្តាយទុកកូនចោលម្នាក់ឯង និងចាញ់បោកគេថានាំទៅធ្វើការនៅប្រទេសថៃ៕

## អង្គការសមាជិកថ្មីរបស់NGOCRC

- អង្គការគ្រីស្ទានកម្ពុជាដើម្បីអភិវឌ្ឍន៍ (CCD)
- អង្គការស្នងការជាតិកម្ពុជាដើម្បីអភិវឌ្ឍន៍ (CCD)
- អង្គការមូលនិធិគាំទ្រកុមារ (CSF)
- អង្គការអប់រំ និងអភិវឌ្ឍន៍ជំនាញពលរដ្ឋកម្ពុជា (EDCS)
- អង្គការកុមារឥតព្រំដែន (KnK) (Children without Borders)
- អង្គការភ្លែន អន្តរជាតិ កម្ពុជា (Plan International Cambodia)
- អង្គការអភិវឌ្ឍន៍វិជ្ជាជីវៈ និងអប់រំ (VDTO)

តមកពីទំព័រទី២

**ខំដាំដុះនៅស្រុកខ្មែរ បែរជាហុចផ្លែផ្កានៅប្រទេសគេទៅវិញ**»។



ចំណែកឯសំដីរបស់ **ប្អូនស្រី ចាន់ពេញល័ក្ខ** អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យសម្តេចក្រុមព្រះនរោត្តមរាណឫទ្ធិអូរអំបិល ខេត្តបន្ទាយមានជ័យបានប្រលងជាប់អាហារូបករណ៍ទៅប្រទេសន័រវេស្ស៍ ប្រាប់ឱ្យដឹងថា «ខ្ញុំសប្បាយចិត្តណាស់ ព្រោះវាជាអ្វីដែលខ្ញុំប៉ង ហើយខ្ញុំអាចធ្វើបាន ហើយធ្វើឱ្យឪពុកម្តាយសប្បាយចិត្ត ម្យ៉ាងទៀតវាជួយសំរាលបន្ទុកគ្រួសារមួយផ្នែកដែរព្រោះថា ជីវភាពគ្រួសាររបស់ខ្ញុំមិនសូវជាធូរធារប៉ុន្មានទេ ហើយអាចធ្វើជាគំរូល្អៗដល់សិស្សប្អូនជំនាន់ក្រោយ»។

«ទៅថ្ងៃអនាគត ខ្ញុំចង់ធ្វើជា IT Expert ផ្នែក Database និងធ្វើការនៅអង្គការមួយដែលទាក់ទងនឹងការអភិវឌ្ឍជនបទ តែដល់ពេលចាស់បន្តិចចង់ធ្វើអ្វីដែលផុសចេញពីគំនិតច្នៃប្រឌិតរបស់ខ្ញុំ ដូចជាសិប្បកម្ម»។ «ដើម្បីឱ្យសំរេចបំណង ខ្ញុំត្រូវខំប្រឹងឱ្យអស់ពីលទ្ធភាពនូវអ្វីដែលខ្ញុំអាចធ្វើទៅបាន ដោយមិនខ្លាចនឿយហត់ ហើយត្រូវមានការតាំងចិត្តថាត្រូវធ្វើអ្វីត្រូវធ្វើឱ្យបាន ត្រូវចេះដាក់ផែនការ ធ្វើផែនការ ដៅយកចំនុចដែលសំខាន់ៗ»

«នៅពេលដែលខ្ញុំទៅរៀននៅប្រទេសគេ ខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើឱ្យល្អបំផុត ក្នុងនាមជាក្មេងស្រីមួយរូបដែលជាតំណាងពីប្រទេសកម្ពុជា ជួយផ្សព្វផ្សាយនូវវប្បធម៌ អរិយធម៌ថាមានអ្វីខ្លះនៅក្នុងប្រទេសកម្ពុជា ដើម្បីទាក់ទាញឱ្យគេចង់ឃើញនិងឱ្យគេមានចិត្តចង់ជួយប្រទេសយើង ហើយនឹងប្រើឱ្យអស់ពីកំលាំងកាយចិត្តធ្វើឱ្យគេចង់ជួយ។ លើសពីនេះទៀត ខ្ញុំត្រូវទំលាប់ឱ្យបាន ក្នុងការរស់នៅប្រទេសគេ ហើយកសាងនូវបរិស្ថានល្អដែលគ្មានអំពើហិង្សា គ្មានការរើសអើង ដែលពោរពេញទៅដោយសាមគ្គីភាព យុត្តិធម៌ សន្តិភាព និងសេចក្តីស្រលាញ់ផងដែរ សំខាន់បំផុតទៀតនោះ គឺខ្ញុំត្រូវធ្វើឱ្យសំរេចនូវគោលដៅរបស់ខ្ញុំឱ្យបាន។»

ជាចុងក្រោយ «ខ្ញុំសូមសំណូមពរចំពោះ UWC ធ្វើយ៉ាងណាសូមជួយផ្តល់អាហារូបករណ៍ឱ្យសិស្សខ្មែរឱ្យបានច្រើនព្រោះថាខ្មែរត្រូវការធនធានមនុស្សជាច្រើន ដើម្បីធ្វើការអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចំរើនថែមទៀត ហើយខ្មែរ គឺជាជនជាតិដែលមានសមត្ថភាពពេញលេញក្នុងការធ្វើការ។ ខ្ញុំសង្ឃឹមថា ឆ្នាំក្រោយនឹងមានអាហារូបករណ៍មកកាន់ប្រទេសកម្ពុជាកាន់តែច្រើនថែមទៀត»៕


## គណៈកម្មការពិនិត្យ

- លោក ជា ពីដែន
- លោក មាស សំណាង
- លោក ម៉ិច សុខា
- លោក យឹម ប៉ូ
- លោកស្រី ថូ ថារី
- លោក ស៊ុំ ចំរុង

## អ្នកគ្រប់គ្រងព័ត៌មាន

- កញ្ញា ផ ស៊ីវហួយ



## គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារ

អាសយដ្ឋានទំនាក់ទំនង: ផ្ទះកុមារ លេខ៨A

ផ្លូវ១៣៨ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ២៣ ៨៨២ ៤១២

ទូរសារ : (៨៥៥) ២៣ ៨៨២ ៤១២

អ៊ីមែល : ch.ngocrc@online.com.kh